Centrelink
Linking Australian Government services

We Speak your **Language**
13 1202

Information
معلومات
Informacije
ពត៌មាន
資 訊
Informacije
Πληροφορίες
Információ
Informazioni
정 보
ຂ່າວຂໍ້ມູນ
Информации
Taghrif
اطلاعات
Informacje
Informação
Информация
Информације
Información
Bilgi
Hướng Dẫn
Інформація

Helping people experiencing Domestic Violence – **Khmer**

# ជំនួយដល់អ្នកដែលជួបប្រទះនឹងអំពើហិង្សាក្នុងគ្រួសារ

អំពើហិង្សាក្នុងផ្ទះនិងក្នុងគ្រួសារ កើតមានឡើងនៅពេលដែលជនមួយរូបព្យាយាមត្រួតត្រាដៃគូ ឬ សមាជិកក្នុងគ្រួសាររបស់ខ្លួន។ អាកប្បកិរិយាត្រួតត្រានេះ អាចមានរួមទាំងការវាយដំ គំរាមកំហែង រំលោភផ្លូវភេទ បំបាក់មុខ កេងប្រវ័ញ្ចប្រាក់កាស និងកាត់ផ្តាច់ចេញពីគេឯង ដូចជាមិនអនុញ្ញាតឲ្យរាប់អានទាក់ទងជាមួយគ្រួសារឬមិត្តភក្តិឡើយ។ ជនរងគ្រោះដោយសារអំពើហិង្សា អាចរស់នៅដោយមានការភ័យបារម្ភសំរាប់ខ្លួនឯងនិងកូនរបស់ខ្លួន សូម្បីតែជនរងគ្រោះនេះបានចាកចេញពីការរស់នៅជាមួយជនប្រើអំពើហិង្សាហើយក៏ដោយ។

## ការប្តូរផ្តាច់របស់ Centrelink ដើម្បីជួយអ្នកដែលជួបប្រទះនឹងអំពើហិង្សា

បើលោកអ្នកស្ថិតនៅក្នុងស្ថានការណ៍គ្រួសារឬក្នុងផ្ទះដែលមានអំពើហិង្សា ឬបើលោកអ្នកបានចាកចេញពីការរស់នៅជាមួយជនប្រើអំពើហិង្សា នោះ Centrelink អាចជួយលោកអ្នកបាន។ យើងអាចផ្តល់ជូនលោកអ្នកនូវពត៌មានអំពីប្រាក់បំណាច់និងសេវាកម្មទាំងឡាយដែលលោកអ្នកអាចមានសិទ្ធិទទួល។ លោកអ្នកក៏អាចសុំជួបជាផ្ទាល់ខ្លួន និងដោយលាក់ការសម្ងាត់ ជាមួយបុគ្គលិកសង្គមកិច្ចរបស់ Centrelink ផងដែរ។

## ដើម្បីជួយអតិថិជនដែលកំពុងជួបប្រទះនឹងអំពើហិង្សាក្នុងផ្ទះនិងក្នុងគ្រួសារ បុគ្គលិក Centrelink នឹងធ្វើការដើម្បីធានាឲ្យមាន:

- សុវត្ថិភាពរបស់លោកអ្នក ដោយមានរួមទាំងវិធានការបន្ថែមដើម្បីការពារភាពផ្ទាល់ខ្លួននិងការសម្ងាត់;
- សេវាកម្មជាបន្ទាន់ រាក់ទាក់ និងមានប្រសិទ្ធភាព ដែលបំពេញទៅតាមសេចក្តីត្រូវការផ្ទាល់ខ្លួនរបស់លោកអ្នកឲ្យបានប្រសើរបំផុត;
- ការពិនិត្យប៉ាន់ស្មង់យ៉ាងត្រឹមត្រូវនិងពេញលេញនូវការឧបត្ថម្ភប្រាក់ចំណូល ដែលអាចឲ្យអតិថិជនទទួលប្រាក់បំណាច់ជាបន្ទាន់ និងមុនពេល ដើម្បីឧបត្ថម្ភខ្លួនគេនិងកូនរបស់គេ នៅពេលដែលមានលទ្ធភាពធ្វើទៅបាន;
- ពត៌មាននិងការបញ្ជូនទៅកាន់សេវាសហគមន៍ឯទៀត;
- ជំនួយភាសាលោកអ្នក តាមរយៈបុគ្គលិកចេះនិយាយពីរភាសា (បើសិនជាមាន) ឬ តាមរយៈអ្នកបកប្រែភាសា។

## ប្រាក់បំណាច់របស់ Centrelink

ដោយអាស្រ័យទៅតាមកាលៈទេសៈរបស់លោកអ្នក លោកអ្នកអាចមានសិទ្ធិទទួលប្រាក់បំណាច់ពី Centrelink ដូចជា Crisis Payment, Parenting Payment, Family Tax Benefit, ឬ Newstart Allowance ។ យើងនឹងគិតគូររកមើលអ្វីៗដែលលោកអ្នកមានសិទ្ធិទទួល ហើយជួយលោកអ្នកក្នុងការដាក់ពាក្យសុំ។

## បុគ្គលិកសង្គមកិច្ច

ការិយាល័យនិងមណ្ឌលសំរាប់ទៅជួបទាំងឡាយរបស់ Centrelink មានបុគ្គលិកសង្គមកិច្ចដែលមានសញ្ញាប័ត្រវិជ្ជាជីវៈ។ យើងអាចរៀបចំឲ្យមានការជួបសំភាសន៍ផ្ទាល់ខ្លួនមួយនៅក្នុងការិយាល័យ ឬមួយបុគ្គលិកសង្គមកិច្ចនេះអាចទៅជួបលោកអ្នកនៅឯផ្ទះ ឬទីកន្លែងមួយទៀត ដូចជាផ្ទះរបស់មិត្តភក្តិ ឬរបស់បងប្អូន ឬ របស់អង្គការសហគមន៍។

## តើលោកអ្នកទើបមកដល់ប្រទេសអូស្ត្រាលីនៅពេលថ្មីៗ ក្នុងភាពជាគូស្រករ ឬ គូដណ្តឹង ហើយជាជនរងគ្រោះនៃអំពើហិង្សាក្នុងផ្ទះឬក្នុងគ្រួសារឬ?

សូមចងចាំថា អំពើហិង្សាក្នុងគ្រួសារគឺជាឧក្រិដ្ឋកម្ម ហើយជាអំពើមិនអាចទទួលយកបាននៅក្នុងប្រទេសអូស្ត្រាលីឡើយ។ លោកអ្នកមិនចាំបាច់ស្ថិតនៅក្នុងស្ថានការណ៍ដែលមានការប្រព្រឹត្តិអំពើហិង្សា ដើម្បីឲ្យមានសិទ្ធិរស់នៅក្នុងប្រទេសនេះឡើយ។

ដើម្បីទទួលពត៌មានជាភាសាក្រៅពីអង់គ្លេស សូមទូរស័ព្ទទៅលេខ **13 1202*** ។
បើកមើលអ៊ីនធើរណិត **www.centrelink.gov.au**

* ទូរស័ព្ទទៅលេខចាប់ផ្តើមដោយលេខ 13 អស់ថ្លៃ 25 សេន ពីគ្រប់ទីកន្លែងទាំងអស់ក្នុងរង្វង់ប្រទេសអូស្ត្រាលី។ ទូរស័ព្ទទៅលេខចាប់ផ្តើមដោយលេខ 1800 ឥតមានគិតថ្លៃទេ។ ទូរស័ព្ទចេញពីទូរស័ព្ទសាធារណៈដែលត្រូវបង់ប្រាក់ ឬ ទូរស័ព្ទចល័ត នឹងត្រូវបង់ថ្លៃតាមអត្រាខ្ពស់ជាងនោះ។

February 2002